NEWS RELEASE

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

**"ដោះស្រាយបញ្ហា មិនមែនព្យាបាលមនុស្សទេ" របាយការណ៍គោលស្តីពីសិទ្ធិក្រុមបុគ្គល LGBT នៅកម្ពុជា ពង្រឹងចលនារបស់ក្រុមបុគ្គល LGBT ក្នុងការអនុវត្តជាក់ស្តែង បទពិសោធន៍ និង អនុសាសន៍**

រាជធានីភ្នំពេញ (៧ សីហា ២០១៤) – ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (ក្រុមបុគ្គល LGBT) នៅកម្ពុជាបន្តប្រឈមនឹងការរំលោភបំពាន និងការរើសអើង នៅតាមលំនៅដ្ឋាន នៅសាលារៀន នៅកន្លែងធ្វើការ និងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ហើយអ្នកតស៊ូមតិដើម្បីសិទ្ធិរបស់ក្រុមបុគ្គល LGBT អំពាវនាវឲ្យមានច្បាប់ និងគោលនយោបាយមានប្រសិទ្ធភាព ដើម្បីការពារពួកគេពីការធ្វើបាប នេះបើតាមរបាយការណ៍ទូលំទូលាយដំបូងគេមានចរិកដូចនេះ ហើយដែលបានចេញផ្សាយនៅថ្ងៃនេះ។

បើតាមរបាយការណ៍របស់អ្នកនិពន្ធ លោក វ៉ាំងសង់ សាឡាស់ "កម្ពុជាគឺជាប្រទេសមួយអព្យាក្រិត្យសម្រាប់ក្រុមបុគ្គល LGBT ៖ មានន័យថា មិនមានការដាក់ទោសទណ្ឌ ហើយក៏គ្មានការបញ្ជាក់វិជ្ជមានណាមួយដែរ"។ ទន្ទឹមនឹងសកម្មភាពភេទដូចគ្នា មិនមែនជាបទល្មើសព្រហ្មទណ្ឌនោះ ច្បាប់ និងគោលនយោបាយរបស់កម្ពុជា នៅស្ងៀមស្ងាត់ អំពីសិទ្ធិរបស់ក្រុមបុគ្គល LGBT នេះបើតាមការសំគាល់របស់របាយការណ៍។ មិនមានច្បាប់ប្រឆាំងនឹងការរើសអើង ឬការដាក់ទោសទណ្ឌចំពោះអ្នកដែលរំលោភសិទ្ធិរបស់ក្រុមបុគ្គល LGBT ឬការនិយាយយោងដល់ការទទួលកេរ្តិ៍មរតក ពន្ធ ឬបញ្ហាសិទ្ធិគ្រួសារ ដែលក្រុមបុគ្គល LGBTបាននិងកំពុងប្រឈម។

បុគ្គល LGBT ជាច្រើន ត្រូវបានគេរាយរាយការណ៍ថា ទទួលបានការប្រព្រឹត្តអវិជ្ជមានពីសំណាក់ក្រុមគ្រួសាររបស់ខ្លួន ចាប់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការប៉ុនប៉ង "ព្យាបាល" ដោយសារតែខ្លួនជាបុគ្គល LGBT ការបដិសេធមិនទទួលស្គាល់ពីគ្រួសារ និងត្រួតពិនិត្យទៅលើឥរិយាបទ។ ការប្រព្រឹត្តនេះបានជំរុញឲ្យបុគ្គល LGBT ត្រូវរត់ចេញពីផ្ទះ ឬបណ្តាលឲ្យ មានបញ្ហាសុខភាពផ្លូវចិត្ត រួមទាំងការបាក់ទឹកចិត្ត និងការកើនឡើងនៃនិន្នាការធ្វើអត្តឃាត។

តំណាងការិយាល័យ OHCHR ប្រចាំកម្ពុជា លោកស្រី វ៉ាន់ ហ៊ី លី បានគូសបញ្ជាក់ថា "ការសិក្សាជាសកលមួយក្នុងឆ្នាំ ២០១១ ដោយការិយាល័យ OHCHR ដែលផ្អែកតាមការសិក្សានេះ មានប្រទេសចំនួន ៨៣ នៅតែចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះឥរិយាបទរបស់ក្រុមបុគ្គល LGBT មានប្រទេសចំនួនប្រាំពីរ ដាក់ទោសប្រហារជីវិតចំពោះទំនាក់ទំនងការរួមភេទដូចគ្នា មានប្រទេសតិចជាង ៥0 ដាក់ទោសចំពោះការរើសអើងប្រឆាំងនឹងក្រុមបុគ្គល LGBT ទាំងស្រុង ឬមួយផ្នែក ហើយមានតែប្រទេសចំនួន ១៩ ប៉ុណ្ណោះ បានហាមឃាត់ការរើសអើងផ្អែកលើអត្តសញ្ញាណយ៉េនឌ័រ"។ "មានកិច្ចការជាក់ច្បាស់ជាច្រើន ដែលត្រូវធ្វើ" លោកស្រីបានបញ្ជាក់បន្ថែម "ខ្ញុំសង្ឃឹមថានឹងឃើញរបាយការណ៍នេះ ត្រូវបានប្រើប្រាស់ដោយមនុស្សរាល់គ្នា ដូច្នេះយើងអាចដោះស្រាយបញ្ហានេះ មិនមែនព្យាបាលមនុស្សនោះទេ"។

"របាយការណ៍នេះ បង្ហាញអំពីឱកាសជាច្រើនខាងគោលនយោបាយ និងច្បាប់ សម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ក្នុងការធ្វើការជាមួយគ្នា ដើម្បីការពារនិងផ្តល់អំណាចច្រើនថែម ទៀតដល់សហគមន៍ LGBT កម្ពុជា" នេះបើតាមប្រសាសន៍របស់ រ៉ូបេក្កា ប្លេក [Rebecca Black] នាយកបេសកកម្មនៃទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID)។ "ច្បាប់គាំទ្រការប្រយុទ្ធប្រឆាំងនឹងការរើសអើងដែលត្រូវបាន

Office of the High Commissioner for Human Rights
Palais des Nations
CH-1211 Geneva 10
Switzerland

www.ohchr.org
Email: press-info@ohchr.org
Tel: +41 22 917 9310
Tel: +41 22 917 9383

អនុវត្ត និងមានការយល់ដឹងល្អនៅកម្រិតសហគមន៍នឹងអាចឲ្យក្រុមបុគ្គល LGBT ចូលរួមយ៉ាងពេញលេញនៅក្នុងសកម្មភាពសង្គម និងរួមចំណែកយ៉ាងធំធេងដល់ការអភិវឌ្ឍន៍កម្ពុជា។ លោកស្រីមានប្រសាសន៍បន្ថែមដូច្នេះ។

"របាយការណ៍ប្រទេសនេះ បានមកពីដំណើរពិគ្រោះយោបល់ ការសិក្សាស្រាវជ្រាវ ការសន្ទនាថ្នាក់ជាតិដែលយើងបានចាប់ផ្តើមធ្វើនៅសរទរដូវកន្លងមក ជាមួយនិងការប្រកាសបើកគម្រោងគំនិតផ្តួចផ្តើមមួយដែលមានឈ្មោះថា ‘Being LGBT in Asia’ ដែលជាភាសាខ្មែរហៅថា (ក្រុមបុគ្គល LGBT នៅអាស៊ី) នៅកម្ពុជា។ របាយការណ៍នេះ ផ្តល់សេចក្តីសង្ខេបអំពីទិដ្ឋភាពទូទៅនៃស្ថានភាពដែលក្រុមបុគ្គល LGBT និងអង្គការសង្គមស៊ីវិលទាំងឡាយដែលធ្វើការក្នុងវិស័យសិទ្ធិក្រុមបុគ្គល LGBT បាននិងកំពុងប្រឈមនៅកម្ពុជា។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) សង្ឃឹមថា ការរកឃើញ និងអនុសាសន៍ទាំងឡាយដែលមាននៅក្នុងរបាយការណ៍នេះ អាចត្រូវបានប្រើប្រាស់ដោយអង្គការសហគមន៍ ទីភ្នាក់ងារនានារបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីយល់ដឹងថែមទៀតអំពីអនាគតរបស់ក្រុមបុគ្គល LGBT និងការរៀបចំធ្វើកម្មវិធីសិទ្ធិមនុស្សនៅក្នុងប្រទេស។ សូរ៉ាវ ជុង ថាផា [Saurav Jung Thapa] មន្ត្រីបច្ចេកទេស ផ្នែកក្រុមបុគ្គល LGBT និងសិទ្ធិមនុស្ស នៃមជ្ឈមណ្ឌលតំបន់អាស៊ីប៉ាស៊ីហ្វិកនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP APRC) ទីក្រុងបាងកក ប្រទេសថៃឡង់ដ៍។

ឃ្លៃ វ៉ាន ឌឺ វ៉ាវ៉ែន [Van der Vaeren] មន្ត្រីសម្របសម្រួលរបស់អ.ស.ប ប្រចាំកម្ពុជា បានសម្តែងការស្ញើចសរសើរដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR កម្ពុជា) ក្នុងភាពជាដៃគូជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មជ្ឈមណ្ឌលតំបន់អាស៊ីប៉ាស៊ីហ្វិក (UNDP APRC) ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) ដែលបានផលិតរបាយការណ៍គោលនេះឡើង។ " ការលើកកម្ពស់សិទ្ធិរបស់ក្រុមបុគ្គល LGBT គឺជាផ្នែកមួយនៃរបៀបវារៈសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ទូលំទូលាយដែលបាននិងកំពុងអនុវត្តនៅកម្ពុជា និងនៅទូទាំងពិភពលោក។ វាគឺនៅពេលដែល ប្រជាជនដែលគេមិនសូវគិតគូដល់ រាប់ទាំងជនភាគតិចខាងផ្លូវភេទ និងយ៉េនឌ័រ ត្រូវបានរួមបញ្ចូលក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ ដែលយើងនឹងធ្វើឲ្យសម្រេចគោលដៅនេះ ដូចមានចែងក្នុងមាត្រា១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស នៃមនុស្សជាតិទាំងអស់ ក្នុងការទទួលបានសិទ្ធិសេរីភាពរបស់ខ្លួនដោយគ្មានការរើសអើង។ ខ្ញុំចូលរួមជាមួយលោកអគ្គលេខាធិការ និងថ្នាក់ដឹកនាំជាន់ខ្ពស់ដទៃទៀត ក្នុងការអំពាវនាវឲ្យមានសិទ្ធិស្មើគ្នាសម្រាប់ក្រុមបុគ្គល LGBT នៅកម្ពុជា" លោកស្រីបានមានប្រសាសន៍ដូច្នេះ។

របាយការណ៍ទូលំទូលាយដំបូងបង្អស់ មិនធ្លាប់មានពីមុនមកនេះ មានចំណងជើងថា " ក្នុងនាមជាក្រុមបុគ្គល LGBT នៅអាស៊ី" ៖ របាយការណ៍របស់កម្ពុជា ស្តីពីសិទ្ធិស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស និងមនុស្សប្តូរភេទ (LGBT) នៅកម្ពុជា នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR កម្ពុជា) ក្នុងភាពជាដៃគូជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មជ្ឈមណ្ឌលតំបន់អាស៊ីប៉ាស៊ីហ្វិក (UNDP APRC) ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។

"របាយការណ៍នេះ ផ្តល់នូវទិដ្ឋភាពទូទៅអំពីក្រុមបុគ្គល LGBT ទាក់ទងនឹងច្បាប់ និងគោលនយោបាយសង្គម និងឥរិយាបថវប្បធម៌ សាសនា កិច្ចការគ្រួសារ ការអប់រំ និងការរៀនសូត្រ ការងារ និងមុខរបរ សហគមន៍ និងសង្គម សុខភាព ព័ត៌មាន និងអនុសាសន៍ សម្រាប់ចលនារបស់ក្រុមបុគ្គល LGBT នៅថ្ងៃពេលអនាគត ។

Office of the High Commissioner for Human Rights
Palais des Nations
CH-1211 Geneva 10
Switzerland

www.ohchr.org
Email: press-info@ohchr.org
Tel: +41 22 917 9310
Tel: +41 22 917 9383

របាយការណ៍របស់ប្រទេសនេះ គឺជាផលិតផលមួយនៃគម្រោងគំនិតផ្តួចផ្តើមទូលំទូលាយមួយ "ក្នុងនាមជាក្រុមបុគ្គល LGBT នៅអាស៊ី៖ ដែលបានប្រកាសបើកជាផ្លូវការនៅក្នុងខែធ្នូឆ្នាំ២០១២ ដែលជាសកម្មភាពនៃការរៀននៅទូទាំងតំបន់អាស៊ីជាលើកដំបូងបង្អស់ ដែលបានធ្វើឡើងដោយអង្គការថ្នាក់មូលដ្ឋានទាំងឡាយដែលធ្វើការក្នុងវិស័យក្រុមបុគ្គល LGBT នៅអាស៊ី និងអ្នកដឹកនាំសហគមន៍ ជាមួយនឹងទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP)។ នៅកម្ពុជា គម្រោងគំនិតផ្តួចផ្តើមនេះ បានធ្វើការក្នុងភាពជាដៃគូជាមួយការិយាល័យ OHCHR ប្រចាំកម្ពុជា។ ដោយការផ្តោតទៅលើប្រទេសចំនួនប្រាំបី គឺប្រទេសកម្ពុជា ចិន ឥណ្ឌូនេស៊ី ម៉ុងហ្គោលី នេប៉ាល់ ហ្វីលីពីន ថៃឡង់ដ៍ និងវៀតណាម) កិច្ចខិតខំប្រឹងប្រែងនេះ ពិនិត្យលើបទពិសោធន៍ជាក់ស្តែងរបស់ក្រុមបុគ្គល LGBT លើទិដ្ឋភាពសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍។

**ចប់**

***អំពីគម្រោងគំនិតផ្តួចផ្តើម ‘Being LGBT in Asia’***

*គម្រោងគំនិតផ្តួចផ្តើមដែលមានឈ្មោះថា ‘Being LGBT in Asia‘ ដែលជាភាសាខ្មែរ ហៅថា (ក្រុម LGBT នៅអាស៊ី) គឺជាគំនិតផ្តួចផ្តើមទីមួយមិនធ្លាប់មានពីមុនមក គឺជាការវិភាគរួមគ្នាមួយ ដែលបានរ៉ាប់រងអនុវត្តដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មជ្ឈមណ្ឌលនៃតំបន់អាស៊ីប៉ាស៊ីហ្វិក (UNDP APRC) បេសកកម្មអភិវឌ្ឍន៍តំបន់អាស៊ីនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និងរួមជាមួយអង្គការ LGBT នៅថ្នាក់មូលដ្ឋាន និងមេដឹកនាំសហគមន៍ដើម្បីស្វែងយល់អំពីបញ្ហាប្រឈមទាំងឡាយដែលក្រុមបុគ្គល LGBT បានជួបប្រទះនៅអាស៊ី។ គំនិតផ្តួចផ្តើមនេះ លើកកំពស់ការយល់ដឹងអំពីបញ្ហាដែលក្រុមបុគ្គល LGBT ប្រឈមទាក់ទងនឹងស្ទិចម៉ា និងការរើសអើង និងជំហានឆ្ពោះទៅរកការងារអភិវឌ្ឍន៍ដែលរួមបញ្ចូលក្រុមបុគ្គល LGBT នៅក្នុងគម្រោងរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ទីភ្នាក់ងារអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និងដៃគូអភិវឌ្ឍន៍ដទៃទៀត តាមរយៈសិក្សាស្រាវជ្រាវ ដូចជារបាយការណ៍នេះ និងការផលិតពហុប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ នៅកម្ពុជា គម្រោងគំនិតផ្តួចផ្តើមនេះ បានធ្វើការក្នុងភាពជាដៃគូជាមួយការិយាល័យ OHCHR ប្រចាំកម្ពុជា។*

*ដើម្បីអានរបាយការណ៍ទាំងស្រុង សូមចូលទៅកាន់៖*
*http://asia-pacific.undp.org/content/rbap/en/home/library/hiv_aids/being-lgbt-in-asia--cambodia-country-report*

*សម្រាប់ព័ត៌មានបន្ថែមអំពី គម្រោងគំនិតផ្តួចផ្តើម ‘Being LGBT in Asia’ សូមចូលទៅកាន់៖*
*beinglgbtinasia.crowdmap.com/page/index/1*

*www.facebook.com/beinglgbt.inasia*

*អំពីសិទ្ធិរបស់ក្រុមបុគ្គល LGBT នៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ*
*ការប្រយុទ្ធប្រឆាំងនឹងការរើសអើងផ្អែកលើនិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ – សូមចូលទៅកាន់៖*
*www.ohchr.org/EN/Issues/Discrimination/Pages/LGBT.aspx*

*អង្គការសហប្រជាជាតិ ដើម្បីសមភាពរបស់ក្រុមបុគ្គល LGBT ៖ អ.ស.ប សេរីភាព និងសមភាព –*
*www.unfe.org/en*

*សម្រាប់សាកសួរព័ត៌មាន សូមទាក់ទង **ប៊ូស្រា រ៉ាម៉ាន់** នៅការិយាល័យ OHCHR ប្រចាំកម្ពុជា តាមរយៈទូរស័ព្ទលេខ*
+៨៥៥០១២ ៧៩០ ១៧៨ ឬអ៊ីម៉េល brahman@ohchr.org)